# បុព្វកថា

- ដោយបានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់អំពីការគោរពសិទ្ធិពលរដ្ឋតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ជឿនលឿននៅលើសកលលោក ។

- ដោយយល់ឃើញថា ចរន្តសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនាពេលបច្ចុប្បន្នបាន នឹងកំពុងមានវឌ្ឍនភាពជាទូទៅគួរឲ្យកត់សំគាល់ ហើយមនុស្សជាតិក្នុងពិភពលោកកំពុងទទួលបាននូវសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ខ្លួនជាបន្តបន្ទាប់ ។

- ដោយយល់ឃើញថា សហស្សវត្សរ៍ថ្មីនៃគ្រឹស្តសករាជឆ្នាំ២០០០នេះ ប្រជាពលរដ្ឋខ្មែរ-កម្ពុជាក្រោមគ្រប់រូប ត្រូវតែសាមគ្គីគ្នាជាធ្លុងមួយក្នុងឆន្ទៈដ៏មុះមុតដើរឲ្យទាន់ចរន្តនៃការវិវឌ្ឍន៍របស់ពិភពលោក ជាពិសេសផ្នែកសិទ្ធិ និងសេរីភាព ដែលយើងជាមនុស្សខ្មែរកម្ពុជាក្រោម ត្រូវតែទទួលបានដូចមនុស្សជាតិលើសកលលោក ។

យើងជាប្រជាពលរដ្ឋខ្មែរដែលមានកំណើតកម្ពុជាក្រោមបានព្រមព្រៀងគ្នាបង្កើតសហគមន៍ខ្មែរកម្ពុជាក្រោមមួយឡើង ដែលជាសហគមន៍មិនរកផលចំណេញជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយមិនធ្វើជាឧបករណ៍នយោបាយ ក្នុងនោះមានរួមទាំងមិនផ្តល់មធ្យោបាយជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយ ដើម្បីតំណាងឆន្ទៈសមាជិកសហគមន៍ ក្នុងការតស៊ូមតិតាមច្បាប់អន្តរជាតិ រហូត ដល់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមទទួលបានសិទ្ធិពេញលេញជាម្ចាស់ដើមនៃទឹកដីកម្ពុជាក្រោម និង ស្របតាមធម្មនុញ្ញនៃអង្គការសហ-ប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារនៃអង្គការសហប្រជាជាតិដែលតម្រូវចាំបាច់ក្នុងកម្រិតអប្បបរមាដែលមនុស្សទូទៅត្រូវតែមាន ។

អាស្រ័យហេតុនេះ យើងសំរេចសរសេរជាច្បាប់សំរាប់គ្រប់គ្រង និងដឹកនាំសហគមន៍ខ្មែរកម្ពុជាក្រោម ដែលមានចែងនៅក្នុងលក្ខន្តិកៈសហគមន៍ខ្មែរកម្ពុជាក្រោមដូចតទៅ៖

# លក្ខន្តិកៈ

# នៃ

# សហគមន៍ខ្មែរកម្ពុជាក្រោម

## ជំពូក ១

## ឈ្មោះ_រូបសញ្ញា_ប្រភេទ_ទីតាំង

**មាត្រា១: អំពីឈ្មោះ សហគមន៍**

សហគមន៍មានឈ្មោះថា **សហគមន៍ខ្មែរកម្ពុជាក្រោម** សរសេរអក្សរកាត់**ស.ខ.ក.ក.** ឈ្មោះជាភាសាអង់គ្លេស :"The Khmer Kampuchea Krom Community" សរសេរកាត់ KKKC ។ អក្សរបារាំង la Communauté du Khmer Kampuchea Krom សរសេរអក្សរកាត់ ckkk ។

**មាត្រា២:** សហគមន៍ខ្មែរកម្ពុជាក្រោមមានរូបប្រាង្គប្រាសាទ និងព្រះចន្ទពេញបូរមីនៅពីលើនៃប្រាសាទជាសញ្ញាសំគាល់ ។

**មាត្រា៣: អំពីប្រវត្តិនិងប្រភេទ**

សហគមន៍ខ្មែរកម្ពុជាក្រោមកើតឡើងដោយឆន្ទៈរបស់សមាជិកសហគមន៍ទាំងពីរភេទ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ខ្មែរ ដែលធ្លាប់រស់នៅលើទឹកដីកម្ពុជាក្រោម ។

- សហគមន៍ខ្មែរកម្ពុជាក្រោមជាសហគមន៍មិនរកប្រាក់ចំណេញជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍នយោបាយ ក្នុងនោះមានរួមទាំងមិនផ្តល់មធ្យោបាយជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ ។

**មាត្រា៤: អំពីទីតាំង**

- សហគមន៍ខ្មែរកម្ពុជាក្រោមមានទីស្នាក់ការកណ្តាលបណ្តោះអាសន្ន នៅអាគារលេខ ១៤ ផ្លូវ ២២១ សង្កាត់ផ្សារដេប៉ូIII ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

## ជំពូក ២

## គោលបំណង _ ទិសដៅ _ តួនាទី

**មាត្រា៥: អំពីគោលបំណង**

- សហគមន៍ខ្មែរកម្ពុជាក្រោមជំរុញការតស៊ូមតិតាមច្បាប់អន្តរជាតិ ដើម្បីឲ្យខ្មែរកម្ពុជាក្រោមទទួលបាននូវសិទ្ធិ និងសេរីភាពពេញលេញ ស្របតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ

ដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ដោយតម្រូវជាចាំបាច់ជាកំរិតអប្បបរមាដែលមនុស្សទូទៅ ត្រូវតែមាន ។

- បណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយ ថែរក្សាការពារ ភាសាសាស្ត្រ អក្សរសាស្ត្រ សាសនា សិល្បៈ វប្បធម៌ បេតិកៈភណ្ឌជាតិ ទំនៀមទំលាប់ និងប្រពៃណីខ្មែរកម្ពុជាក្រោម ។

មាត្រា៦: **អំពីទិសដៅ**

- ធ្វើសកម្មភាពតំណាងឆន្ទៈសមាជិកសហគមន៍ខ្មែរកម្ពុជាក្រោម ក្នុងក្របខណ្ឌសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ។

- តស៊ូមតិនិងធ្វើរាល់កិច្ចការដែលទាក់ទងដល់សិទ្ធិ សេរីភាព ភាសាសាស្ត្រ អក្សរសាស្ត្រ សាសនា សិល្បៈ វប្បធម៌ បេតិកភណ្ឌជាតិ ទំនៀមទំលាប់ និងប្រពៃណីខ្មែរកម្ពុជាក្រោម ស្របតាមច្បាប់អន្តរជាតិ ។

- ធ្វើអន្តរាគមន៍ដោយអហិង្សាតាមគ្រប់រូបភាព ដើម្បីទប់ស្កាត់រាល់ការរើសអើងនិងការរំលោភនានាមកលើប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ។

- ស្វែងរកមូលនិធិសំរាប់បណ្តុះបណ្តាលធនធានមនុស្ស អប់រំផ្សព្វផ្សាយ ថែរក្សាការពារ ភាសាស្ត្រ អក្សរសាស្ត្រ សាសនា សិល្បៈវប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីខ្មែរកម្ពុជាក្រោមតាមលទ្ធភាព ។

- ស្រាវជ្រាវនិងបោះពុម្ពផ្សាយឯកសារនានាដែលទាក់ទងដល់ប្រវត្តិទឹកដីកម្ពុជាក្រោម។

- ទំនាក់ទំនងជាមួយសហគមន៍ជាតិ និងអន្តរជាតិ ។

មាត្រា៧: **អំពីតួនាទី និងភារកិច្ចសហគមន៍**

១- អនុវត្តផែនការណ៍នានាដែលកំណត់ដោយអង្គមហាសន្និបាត ។

២-ទំនាក់ទំនងជាមួយរដ្ឋាភិបាល-សហគមន៍ជាតិអន្តរជាតិដើម្បីសម្របសម្រួលការងារ,បង្កើតកម្មវិធីដើម្បីតស៊ូមតិ និងប្រមូលទិន្នន័យនៃបញ្ហាទាំងឡាយដែលកើតឡើងចំពោះជនរួមឈាមខ្មែរកម្ពុជាក្រោម ។

## ជំពូក ៣

## សមាជិកភាព

មាត្រា៨: **អំពីសមាជិកភាព**

១-ប្រជាពលរដ្ឋខ្មែរទាំងពីរភេទអាចចូលជាសមាជិកសហគមន៍ខ្មែរកម្ពុជាក្រោម ដោយមិនប្រកាន់និន្នាការនយោបាយ ឬសាសនា ។

មាត្រា៩: សមាជិករបស់សហគមន៍ខ្មែរកម្ពុជាក្រោមចែកចេញជាប្រាំប្រភេទគឺៈ

១- សមាជិកស្ថាបនិក

២- សមាជិកកិត្តិយស

៣- សមាជិកសកម្ម

៤- សមាជិកឧបត្ថម្ភ

៥- សមាជិកបាសាទិកៈ ។

មាត្រា១០: សមាជិកស្ថាបនិក គឺជាសមាជិកដែលបានផ្តួចផ្តើមគំនិតបង្កើតសហគមន៍ខ្មែរកម្ពុជាក្រោម។

មាត្រា១១: សមាជិកកិត្តិយស គឺជាវរជនដែលមានកិត្តិនាមលើឆាកជាតិនិងអន្តរជាតិឬវរជនដែលមានគុណបំណាច់ចំពោះទឹកដីមាតុភូមិកម្ពុជាក្រោម ។

មាត្រា១២: សមាជិកសកម្ម គឺជាសមាជិកដែលខិតខំបំពេញកិច្ចការគ្រប់បែបយ៉ាង ក្នុងស្មារតីក្លាហានមោះមុតនិងស្មោះត្រង់ចំពោះសហគមន៍ខ្មែរកម្ពុជាក្រោម ។

មាត្រា១៣: សមាជិកឧបត្ថម្ភ គឺជាសមាជិកផ្តល់ការឧបត្ថម្ភគាំទ្រជាសម្ភារៈឬថវិកាដល់សហគមន៍ខ្មែរ-កម្ពុជាក្រោម ។

មាត្រា១៤: សមាជិកបាសាទិកៈ គឺជាសមាជិកគាំទ្រយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែមិនបានចូលរួមធ្វើសកម្មភាពផ្ទាល់ជាមួយសហគមន៍ ។

មាត្រា១៥: សមាជិកសហគមន៍ទាំងអស់ អាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយៈ

១- ទទួលមរណភាព ។

២- សុំលាលែងជាលាយលក្ខណ៍អក្សរជូននាយកប្រតិបត្តិសហគមន៍ ។

៣-គណៈកម្មាធិការប្រតិបត្តិសហគមន៍ លុបឈ្មោះចេញពីសហគមន៍ដោយសារសមាជិកនោះបានប្រព្រឹត្តផ្ទុយពីលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍។

## ជំពូក ៤

## ថវិកា

មាត្រា១៦: **ប្រភពថវិកា**

ថវិការបស់សហគមន៍បានមកពីៈ

- អំណោយឧបត្ថម្ភរបស់សមាជិក សមាជិកា ។
- វិភាគទានរបស់សមាជិក សមាជិកា ។
- អំណោយពីសប្បុរសជននានា, អង្គការមូលនិធិជាតិ និងអន្តរជាតិ ។
- សកម្មភាពស្របច្បាប់ក្នុងគ្រប់វិស័យ ។

មាត្រា១៧: **នីតិវិធីគ្រប់គ្រង**

- ថវិការបស់សហគមន៍ខ្មែរកម្ពុជាក្រោម ត្រូវរក្សាទុកក្នុងធនាគារស្ថិតនៅក្រោមការត្រួតពិនិត្យនិងគ្រប់គ្រងរបស់គណៈកម្មាធិការប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម ។

- រាល់ការបញ្ចេញបញ្ចូលថវិកានៅធនាគារ ត្រូវមានការយល់ព្រមពីនាយកគណៈកម្មាធិការប្រតិបត្តិហេរញ្ញិក ហេរញ្ញិករង ឬការយល់ព្រមដោយមតិ២ភាគ៣ នៃអង្គ ប្រជុំគណៈកម្មា-ធិការប្រតិបត្តិ ។

- រាល់ការចំណាយត្រូវមានការឯកភាពពីអ្នកសម្របសម្រួល ដោយផ្អែកលើគំរោងដែលអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិបានអនុម័ត ។

- មន្ត្រីហិរញ្ញវត្ថុជាអ្នកទទួលខុសត្រូវលើការទូទាត់ថវិកា និងត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដើម្បីធានាគណនេយ្យភាពនិងតម្លាភាព ។

## ជំពូក ៥

## រចនាសម្ព័ន្ធ

មាត្រា១៨: **រចនាសម្ព័ន្ធរបស់សហគមន៍មាន:**

- មហាសន្និបាត ។
- ក្រុមប្រឹក្សាភិបាល ។
- គណៈកម្មាធិការប្រតិបត្តិ ។
- គណៈកម្មាធិការវិន័យនិងដោះស្រាយវិវាទ ។

## ជំពូក ៦

## មហាសន្និបាត

មាត្រា១៩: មហាសន្និបាត គឺជាស្ថាប័នកំពូលរបស់សហគមន៍ខ្មែរកម្ពុជាក្រោម ។មហាសន្និបាតចូលរួមដោយសមាជិកសហគមន៍ខ្មែរកម្ពុជាក្រោមទាំងអស់ តាមការអញ្ជើញពីសហគមន៍ខ្មែរកម្ពុជា-ក្រោម ។ មហាសន្និបាតកំណត់ទិសដៅ និងផែនការនានារបស់ សហគមន៍, អនុម័តសេចក្តីសំរេចសំខាន់ៗ ដែលគណៈកម្មាធិការប្រតិបត្តិសហគមន៍ដាក់ជូន ។មហាសន្និបាតបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលជ្រើស តាំងប្រធាន អនុប្រធាន លេខា-ធិការរបស់ខ្លួន និងបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការប្រតិបត្តិ ។ ការបោះឆ្នោតដែលយកជាការបានគឺត្រូវ មានសម្លេងភាគច្រើនដាច់ខាតនៃសមាជិកសហគមន៍ដែលវត្តមាន ។

មាត្រា២០: មហាសន្និបាតមានពីរប្រភេទ គឺមហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ ។

- មហាសន្និបាតសាមញ្ញធ្វើឡើងនៅរៀងរាល់០៣ឆ្នាំម្តង ។ កាលបរិច្ឆេទនៃមហាសន្និបាតកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ។
- មហាសន្និបាតវិសាមញ្ញធ្វើឡើងតាមសំណើ២ភាគ៣នៃសមាជិកក្រុមប្រឹក្សាភិបាល ឬតាមសំណើ២ភាគ៣នៃសមាជិកសមាជិកាគណៈកម្មាធិការប្រតិបត្តិ ។

មាត្រា២១: ការអញ្ជើញសមាជិក ត្រូវធ្វើឡើង៣សប្តាហ៍មុនធ្វើមហាសន្និបាតសាមញ្ញ ។រីឯការអញ្ជើញសមាជិកចូលរួមមហាសន្និបាតវិសាមញ្ញ ត្រូវធ្វើឡើងមុនពេលពីរសប្តាហ៍ ។ លិខិតអញ្ជើញត្រូវភ្ជាប់ដោយរបៀបវារៈត្រឹមត្រូវ ។

## ជំពូក ៧

## ក្រុមប្រឹក្សាភិបាល

មាត្រា២២: ក្រុមប្រឹក្សាភិបាល ជាស្ថាប័នតំណាងមហាសន្និបាតរបស់សហគមន៍ ។ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការអនុវត្តន៍ទិសដៅនិងផែនការរបស់សហគមន៍ ដែលមហាសន្និបាតបានកំណត់ ។

ក្រុមប្រឹក្សាភិបាលសហគមន៍ មានសមាជិកយ៉ាងតិច០៩រូប ដែលជ្រើសរើសដោយ មហាសន្និបាតសំរាប់អាណត្តិ០៣ឆ្នាំ ។ អាណត្តិរបស់ក្រុមប្រឹក្សាភិបាលត្រូវបញ្ចប់នៅពេលក្រុមប្រឹក្សាភិបាលថ្មីមកជំនួស ។

មាត្រា២៣: ក្រុមប្រឹក្សាភិបាលសហគមន៍ បង្កើតគណៈកម្មាធិការប្រតិបត្តិនិងគណៈកម្មការវិន័យនិងវិវាទ ដោយជ្រើសរើសចេញពីសមាជិករបស់ខ្លួនតាមរយៈការបោះឆ្នោតដោយសម្លេងភាគច្រើនដាច់ខាត ។

- សមាជិក្រុមប្រឹក្សាភិបាលត្រូវប្រជុំ០៣ខែម្តង ។ ការប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាល ធ្វើឡើងតាមសំណើ២ភាគ៣ពីសមាជិកក្រុមប្រឹក្សាភិបាលឬពីសមាជិកគណៈកម្មាធិការប្រតិបត្តិ។

## ជំពូក ៨

## គណៈកម្មាធិការប្រតិបត្តិ

មាត្រា២៤: គណៈកម្មាធិការប្រតិបត្តិ ជាស្ថាប័នខ្ពស់បំផុតក្នុងការដឹកនាំសហគមន៍ខ្មែរកម្ពុជាក្រោម។គណៈ-កម្មាធិការប្រតិបត្តិអនុវត្តទិសដៅនិងផែនការនានារបស់សហគមន៍ ដែលបានកំណត់ដោយមហាសន្និបាត ក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល ។

- គណៈកម្មាធិការប្រតិបត្តិធានាដំណើរការនិងគ្រប់គ្រងសកម្មភាពប្រចាំថ្ងៃរបស់សហគមន៍។

- គណៈកម្មាធិការប្រតិបត្តិមានសមាជិកយ៉ាងតិច០៥រូប ដែលត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល តាមនីតិវិធីដូចមានចែងក្នុងមាត្រា២៣ សំរាប់អាណត្តិ៣ឆ្នាំ។ អាណត្តិគណៈកម្មាធិការប្រតិបត្តិ ត្រូវបញ្ចប់នៅពេលដែលគណៈកម្មាធិការប្រតិបត្តិថ្មីចូលកាន់តំណែង។

មាត្រា២៥: គណៈកម្មាធិការប្រតិបត្តិដឹកនាំដោយនាយក១រូប, នាយករងយ៉ាងតិច២រូប និងមាននាយលេខាធិការដ្ឋាន និងនាយការិយាល័យនានា ប្រធានសាខាខេត្ត-ក្រុងនិងនៅបរទេស ។ គណៈកម្មាធិការប្រតិបត្តិប្រជុំសាមញ្ញរៀងរាល់ដំណាច់ខែនីមួយៗ និងប្រជុំវិសាមញ្ញនៅពេលចាំបាច់ ។

មាត្រា២៦: នាយកប្រតិបត្តិ គឺជាកុលបុត្រខ្មែរទាំងពីរភេទដែលមានសមត្ថភាពប្រជាប្រិយភាព និងលទ្ធភាពដឹកនាំសហគមន៍ ។ នាយកប្រតិបត្តិត្រូវបានជ្រើសរើសតាមការបោះឆ្នោតរបស់ក្រុមប្រឹក្សាភិបាលដោយសម្លេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនសមាជិកចូលរួមយ៉ាងតិច២ភាគ៣ ។

មាត្រា២៧: កូរ៉ុមនៃការប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិគឺ២ភាគ៣ នៃសមាជិកទាំងអស់ ។

មាត្រា២៨: ការអនុម័តដែលអាចយកជាការបានរបស់គណៈកម្មាធិការប្រតិបត្តិគឺដោយសម្លេងភាគច្រើនដាច់ខាត(៥០+១)នៃសមាជិកវត្តមាននៅក្នុងអង្គប្រជុំ ។

## ជំពូក ៩

## គណៈកម្មាធិការវិន័យ និងដោះស្រាយវិវាទ

មាត្រា២៩: គណៈកម្មាធិការវិន័យនិងដោះស្រាយវិវាទ ត្រូវបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលសហគមន៍ តាមរយៈការបោះឆ្នោតជ្រើសរើសចេញពីសមាជិករបស់ខ្លួន ។ ការបោះឆ្នោតនេះយកជាការបានគឺដោយ សម្លេងភាគច្រើនដាច់ខាត(៥០+១) ។

មាត្រា៣០: គណៈកម្មាធិការវិន័យ និងដោះស្រាយវិវាទ មានសមាជិកយ៉ាងតិច៥រូបគឺ ប្រធាន១ រូបអនុ-ប្រធាន១រូប, លេខាធិការ១រូប និងសមាជិកយ៉ាងតិច២រូប ។

មាត្រា៣១: តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការវិន័យ និងដោះស្រាយវិវាទ

-រៀបចំសរសេរវិន័យរបស់សហគមន៍

-ទទួលពាក្យបណ្តឹងនានារបស់សមាជិកសហគមន៍ដែលមានវិវាទនឹងគ្នាដើម្បីផ្សះផ្សាឬដោះស្រាយ។

## ជំពូក ១០

## ការកែប្រែលក្ខន្តិកៈ និងការរំលាយសហគមន៍

មាត្រា៣២: មហាសន្និបាតសហគមន៍ជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចកែប្រែលក្ខន្តិកៈ ឬរំលាយសហគមន៍ ។

- ការកោះប្រជុំមហាសន្និបាតក្នុងគោលបំណងកែប្រែលក្ខន្តិកៈឬរំលាយសហគមន៍ ត្រូវមានការយល់ព្រមដោយមតិ២ភាគ៣នៃគណៈកម្មាធិការប្រតិបត្តិឬមតិពីរភាគបីនៃក្រុមប្រឹក្សាភិបាលសហគមន៍ ។

- ក្នុងករណីដែលសហគមន៍ខ្មែរកម្ពុជាក្រោមត្រូវរំលាយធនធានទាំងអស់របស់សហគមន៍ ត្រូវប្រគល់ជូនអង្គការមនុស្សធម៌នានាដែលកំណត់ដោយមហាសន្និបាតចុងក្រោយរបស់សហគមន៍ ៕

*លក្ខន្តិកៈនេះត្រូវបានអង្គប្រជុំអនុម័តជាឯកច្ឆន្ទៈនៅថ្ងៃច័ន្ទ ទី ២១ ខែតុលា ឆ្នាំ២០០២*
*ត្រូវនឹងថ្ងៃពេញបូរមី ខែអស្សុជ ឆ្នាំមមី ចត្វាស័ក ពុទ្ធសករាជ ២៥៤៦*
*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២*

**នាយកប្រតិបត្តិ**



**ថាច់ សេដ្ឋា**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

*លេខ :..៣១១ សៈជ.៣*

រាជធានីភ្នំពេញ,ថ្ងៃទី..២៥..ខែ..មី.ណា..ឆ្នាំ២០០៣

## ជំរាបមក

**លោក ថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម**

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់ ***សហគមន៍ខ្មែរកម្ពុជាក្រោម*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ ***គ្មាន*** ចុះថ្ងៃទី ***២៩*** ខែ ***តុលា*** ឆ្នាំ ***២០០២*** ស្តីពីការសុំចុះបញ្ជីរបស់ ***សហគមន៍ខ្មែរកម្ពុជាក្រោម*** ។

តបតាមកម្មវត្ថុ និង យោងខាងលើ សូមជំរាបលោកប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី ***សហគមន៍ខ្មែរកម្ពុជាក្រោម*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅផ្ទះលេខ***១៤DE₀*** ផ្លូវលេខ ***២២១*** សង្កាត់ ***ផ្សារដេប៉ូទី៣*** ខណ្ឌ ***ទួលគោក រាជធានីភ្នំពេញ*** នោះហើយ ។ ***សហគមន៍ខ្មែរកម្ពុជាក្រោម*** ត្រូវអនុវត្តតាមលក្ខន្តិកៈ ដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបំរើអោយគណបក្សនយោបាយ មិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សហគមន៍ខ្មែរកម្ពុជាក្រោម ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មី ដោយបំពេញល័ក្ខខ័ណ្ឌផ្សេងៗ អោយបានត្រឹមត្រូវតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាពត៌មាន ។

សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**សហរដ្ឋមន្ត្រី**

ស ខេង                យូ.ហុកគ្រី

***ចម្លងជូន***

- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាក្រុងភ្នំពេញ
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

រចនាសម្ព័ន្ធសមាគមន៍ខ្មែរកម្ពុជាក្រោម




ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

នាយកប្រតិបត្តិ

ថាច់ សេដ្ឋា